ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២២២ សហវ

ភ្នំពេញ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន
## នៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/.នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញច្បាប់ស្តីពី ប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១.នស.ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១.នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះ រាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រងឆ្នាំ ២០០២ ។

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។

-បានឃើញប្រកាសលេខ ០០៤ សហវ/មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។

-បានឃើញលិខិតលេខ ១១៥/សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។

-បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរង្វាន់ទេយ្យបុរេប្រទាន ។

-បានឃើញប្រកាសលេខ ១២៩ ប្រក/សហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រង្វាន់ទេយ្យបុរេប្រទានជំពូក១១ សំរាប់ទូទាត់ចំណាយចាំបាច់ទៅលើដំណើរការ រដ្ឋបាល សំភារៈ និង ការជួសជុលតូច ។

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន ។

<u>**សំរេច**</u>

ប្រការ១ : ត្រូវបានបង្កើតរង្វាន់ទេយ្យបុរេប្រទានជំពូក១១ នៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដើម្បីទូទាត់ចំណាយទាំងឡាយណាដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរមា នៃចំណាយដែលអនុញ្ញាតអោយ រង្វាន់ទេយ្យ ករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្រោម ៥០០.០០០រ០០( ប្រាំរយពាន់រៀលគត់ ) តាមចំណោត់ថ្នាក់ចំណាយនិមួយៗ ដូច មានចែងក្នុងតារាង ឧបសម្ព័ន្ធភ្ជាប់ជ.មួយនូវប្រកាសអន្តរក្រសួង ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃរង្វាន់ទេយ្យបុរេប្រទានជំពូក១១សំរាប់មួយជុំនៃឆ្នាំត្រូវបានកំណត់ត្រឹមចំនួន ៧៦.០០០.០០០រ០០ (ចិតសិបប្រាំមួយលានរៀលគត់) ។

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានធនាគារជាតិ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន គ្រប់អង្គភាពពាក់ពន្ធ័ទាំងអស់ក្រោមឱវាទក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/៕

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**អ៊ិត សំហេង**

<u>**កន្លែងទទួល**</u>

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការបួន ដើម្បីមុខការ
-ឯកសារ - កាលប្បវត្តិ